ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ

នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៥៤៧..................អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារ សូមជូនដំណឹងដល់លោក លោកស្រី និងនាងកញ្ញាដែលជាបេក្ខជនទើបប្រឡងជាប់ជាមន្ត្រីពន្ធដារថ្មីក្របខ័ណ្ឌ ក ខ និងគ ចំនួន ២៨៩ នាក់ ឱ្យបានជ្រាបថា យោងតាមប្រកាសលេខ០៨៩ សហវ.ប្រក.ប ចុះ ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១២ និងប្រកាសលេខ ០៩០ សហវ.ប្រក.ប ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការទទួលស្គាល់មន្ត្រីរាជការឱ្យចូលបំរើការងារនៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោយពីបានសិក្សាចប់សព្វគ្រប់នូវវគ្គសិក្សាជំនាញពន្ធដារ សូមលោក លោកស្រីនាងកញ្ញាអញ្ជើញមកជួបជុំនៅ**សាលាជាតិពន្ធដារ ជាន់ទី១០ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ វេលាម៉ោង ២.០០ រសៀល ជាកំណត់ ដោយស្លៀកពាក់ឯកសណ្ឋានពន្ធដារ** ដើម្បីងាយស្រួលក្នុងការទទួលព័ត៌មាន ស្តីពីការចាត់បញ្ជូនទៅបំរើការងារនៅតាមអង្គភាពរៀងៗខ្លួន ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា លោក លោកស្រី នាងកញ្ញានឹងមកជួបជុំគ្នាតាមកាលកំណត់ខាងលើកុំបីខានឡើយ ។

សូមលោក លោកស្រី នាងកញ្ញាទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

ស៊ឹម-អៀង

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០

CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH Phone: (855) 23 886 708/ Fax: (885) 23 886 700